**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់សហគមន៍ នៃតំបន់ឧទ្យានជាតិព្រះសីហនុ "រាម" ស្ថិតក្នុងភូមិសាស្ត្រភូមិ អុង ឃុំ រាម ស្រុក ព្រៃនប់ ខេត្ត ព្រះសីហនុ

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

មាត្រា១:

ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ឧទ្យានជាតិព្រះសីហនុ "រាម" លើផ្ទៃដីទំហំ ៨៤,៥ ហិកតា (ប៉ែតសិបបួនហិកតា និងប្រាំអា) ទៅជាតំបន់សហគមន៍ ស្ថិតនៅក្នុងភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។

មាត្រា២:

តំបន់សហគមន៍ក្នុងតំបន់ឧទ្យានជាតិព្រះសីហនុ "រាម" ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធកំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមកាដូចខាងក្រោមៈ

| N° | X | Y | N° | X | Y | N° | X | Y |
|---|---|---|---|---|---|---|---|---|
| A | ៣៤៨៨៦៥ | ១១៦៤០៨៦ | J | ៣៥០១៣៥ | ១១៦៥៤០៤ | S | ៣៥០៦៧២ | ១១៦៧៣៥២ |
| B | ៣៤៩០០៩ | ១១៦៤២២៩ | K | ៣៥០១២៥ | ១១៦៥៦៣៣ | T | ៣៥០៥០១ | ១១៦៧១៤៤ |
| C | ៣៤៩១២៩ | ១១៦៤៣០៣ | L | ៣៥០១៥៥ | ១១៦៥៨២០ | U | ៣៥០៣៦១ | ១១៦៧០១០ |
| D | ៣៤៩២៨៥ | ១១៦៤៣៣៣ | M | ៣៥០១៤២ | ១១៦៦១៣៥ | V | ៣៥០០២៧ | ១១៦៦៤៥៤ |
| E | ៣៤៩៤៥៤ | ១១៦៤៤២៥ | N | ៣៥០២២៧ | ១១៦៦៣៨១ | W | ៣៥០០០៣ | ១១៦៥៦១០ |
| F | ៣៤៩៧២៤ | ១១៦៤៣៨៥ | O | ៣៥០៥៣៤ | ១១៦៦៦៧៨ | X | ៣៤៩៨២៨ | ១១៦៥០០៨ |
| G | ៣៤៩៩២៣ | ១១៦៤៧៣១ | P | ៣៥០៧០៤ | ១១៦៦៩៦២ | Y | ៣៤៨៩៦៧ | ១១៦៤៣៦៨ |
| H | ៣៤៩៩៦៥ | ១១៦៤៩៥៥ | Q | ៣៥០៧៩១ | ១១៦៧១៦៩ | Z | ៣៤៨៨៣៤ | ១១៦៤១១៥ |
| I | ៣៥០០៥៧ | ១១៦៥២៨៩ | R | ៣៥០៨៤៩ | ១១៦៧២៦៨ | | | |

**មាត្រា៣:**

ការកំណត់តំបន់សហគមន៍ស្ថិតក្នុងភូមិសាស្ត្រភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ជាតំបន់គ្រប់គ្រង បម្រើឲ្យការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍មូលដ្ឋានដែលកំពុងមានសកម្មភាពស្រាប់ រួមមានៈ លំនៅឋាន ស្រែចម្ការ។ រាល់ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឲ្យប្រើប្រាស់ដីធ្លី នៅក្នុងតំបន់សហគមន៍នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល ។

**មាត្រា៤:**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៥:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១១.

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

## ផែនទី កំណត់តំបន់សហគមន៍ នៃតំបន់ឧទ្យានជាតិព្រះសីហនុ "រាម"
## ស្ថិតនៅក្នុងភូមិអូរ ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ លើផ្ទៃដីចំនួន ៨៤,៥ ហិកតា

អនុក្រឹត្យ លេខ: ១៤ អនក្រ.បក..........
ចុះថ្ងៃទី ...១៤... ខែ មករា..... ឆ្នាំ ២០១១..






សញ្ញាសម្គាល់
- ○ ចំណុចនិយាមការ
- តំបន់សហគមន៍
- ព្រំប្រទល់តំបន់ការពារធម្មជាតិ
- ផ្លូវជាតិ
- ផ្លូវលំ
- អូរ ព្រែក សមុទ្រ

| Lp | Coor_X | Coor_Y | Lp | Coor_X | Coor_Y |
|---|---|---|---|---|---|
| A | 348865 | 1164086 | N | 350227 | 1166381 |
| B | 349009 | 1164229 | O | 350534 | 1166678 |
| C | 349129 | 1164303 | P | 350704 | 1166962 |
| D | 349285 | 1164333 | Q | 350791 | 1167169 |
| E | 349454 | 1164425 | R | 350849 | 1167268 |
| F | 349724 | 1164385 | S | 350672 | 1167352 |
| G | 349923 | 1164731 | T | 350501 | 1167144 |
| H | 349965 | 1164955 | U | 350361 | 1167010 |
| I | 350057 | 1165289 | V | 350027 | 1166454 |
| J | 350135 | 1165404 | W | 350003 | 1165610 |
| K | 350125 | 1165633 | X | 349828 | 1165008 |
| L | 350155 | 1165820 | Y | 348967 | 1164368 |
| M | 350142 | 1166135 | Z | 348834 | 1164115 |

0 0.5 1
Kilometers

Spheroid ........................................ Everest
Grid .......... 1,000 Meter... ......UTM: Zone48N
Projection ........ Transverse mercator
Horizontal Datum .............. Indian_1960